# ឱកាសការងារពី អេ អឹម ខេ

អេ អឹម ខេ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលឈានមុខគេមួយក្នុងប្រទេសកម្ពុជា ដែលមានបណ្តាញប្រតិបត្តិការទូទាំង ប្រទេស។ បច្ចុប្បន្ននេះ អេ អឹម ខេ មានបុគ្គលិកជាង ៣,៧០០ នាក់ ដែលកំពុងបម្រើសេវាហិរញ្ញវត្ថុជូនដល់អតិថិជនប្រមាណជាង ១.០០០.០០០ នាក់ ក្នុងភូមិសរុបចំនួន ១៣.០០០ភូមិ ដែលស្មើនឹង ៩១ % ក្នុងប្រទេសកម្ពុជា។ ឥឡូវនេះ អេ អឹម ខេ ត្រូវការជ្រើសរើសបុគ្គលិកដែល មានសមត្ថភាព និងប្តេជ្ញាចិត្តខ្ពស់ចូលរួមជាមួយនឹងក្រុមការងារដ៏ច្រើនសម្បូរបែបនៅគ្រប់ការិយាល័យសាខា និងបណ្តានាយកដ្ឋានទាំងអស់ទូទាំងប្រទេស សម្រាប់បំពេញនូវតម្រូវការអាជីវកម្ម។ ចូលជាសមាជិកគ្រួសារ អេ អឹម ខេ លោកអ្នកមិនត្រឹមតែទទួលបាននូវប្រាក់បៀវត្សមួយមុខប៉ុណ្ណោះទេ អេ អឹម ខេ នឹងជួយ អ្នកក្នុងការអភិវឌ្ឍសមត្ថភាព និងទេពកោសល្យការងារដើម្បីឆ្ពោះទៅរកភាពរីកចម្រើននាពេលអនាគត។

---

| | |
|---|---|
| **មុខតំណែង:** | **បុគ្គលិកហាត់ការរៀនសូត្រ ផ្នែកលក់ ( ចំនួន ៨០ នាក់ )** |
| **ទីតាំងត្រូវបំពេញការងារ:** | **ប្រចាំនៅគ្រប់ការិយាល័យសាខារបស់ អេ អឹម ខេ** |
| **កាលបរិច្ឆេទឈប់ទទួលពាក្យ:** | **ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០២៥** |

---

## ការងារនិងទំនួលខុសត្រូវសម្រាប់បុគ្គលិកហាត់ការរៀនសូត្រ៖

- ផ្សព្វផ្សាយផលិតផល និងធ្វើការលក់សេវាកម្មនានា ផ្នែកឥណទានរបស់ អេ អឹម ខេ ជូនដល់អតិថិជនគោលដៅ
- ជួយរៀបចំគម្រោងចុះផ្សព្វផ្សាយ និងគម្រោងផែនការលក់
- ជួយរៀបចំឯកសារឬដំណើរការនានា ដើម្បីពន្លឿនដល់ការទម្លាក់ទុនកម្ចីជូនដល់អតិថិជន
- ជួយណែនាំអតិថិជនគោលដៅ ឱ្យមកប្រើប្រាស់ផលិតផលឬសេវាកម្មរបស់ អេ អឹម ខេ
- សិក្សាស្វែងយល់ និងផ្តល់ជាគំនិតកែលំអបន្ថែមដើម្បីពង្រីកវិសាលភាពរបស់ អេ អឹម ខេ
- រក្សាទំនាក់ទំនងល្អជាមួយក្រុមការងារ អតិថិជន និងភាគីពាក់ព័ន្ធនានា
- ជួយសម្របសម្រួលការងារផ្សេងៗទៀតប្រសិនបើមានការស្នើសុំ។

## លក្ខខណ្ឌក្នុងការជ្រើសរើស៖

- មានកម្រិតវប្បធម៌យ៉ាងហោចណាស់បានបញ្ចប់ថ្នាក់ទី១២ ដោយជោគជ័យ ឬ សញ្ញាប័ត្រដែលមានតម្លៃស្មើ
- មិនទាមទារបទពិសោធន៍ការងារ
- ចូលចិត្តក្នុងការរៀនសូត្របន្ថែម និងទទួលមតិកែលំអ
- មានទំនាក់ទំនងល្អ មានជំនាញប្រាស្រ័យទាក់ទង មានភាពស្មោះត្រង់ និងពូកែដោះស្រាយបញ្ហា
- មានឆន្ទៈធ្វើការយ៉ាងជិតស្និទ្ធិជាមួយសហគមន៍ អតិថិជនគោលដៅ ឬភាគីពាក់ព័ន្ធនានា
- ត្រូវចេះអានភាសាអង់គ្លេស និងអាចប្រើប្រាស់កុំព្យូទ័របានបន្តិចបន្តួច។

## អត្ថប្រយោជន៍ដែលទទួលបាន៖

- ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ
- ទទួលបានការគាំពារពី បេឡាជាតិសន្តិសុខសង្គម និងធានារ៉ាប់រងអាយុជីវិត ២៤ម៉ោង (បសស)
- ឱកាសទទួលបានការអភិវឌ្ឍខ្លួន និងវគ្គបណ្តុះបណ្តាលលើវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ
- ទទួលបានបទពិសោធន៍លើការផ្សព្វផ្សាយ ការទម្លាក់ទុន ការប្រមូលប្រាក់កម្ចី និងការវាយតម្លៃកម្ចី
- ទទួលបានឱកាសខ្ពស់ក្លាយជាបុគ្គលិកពេញសិទ្ធិជាមួយ អេ អឹម ខេ
- ទទួលបានលិខិតបញ្ជាក់ការងារពី អេ អឹម  ខេ។

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេបនិងពាក្យសុំបំរើការងារ(CV and Cover Letter)មកកាន់ការិយាល័យ អេ អឹម ខេ គ្រប់សាខា ឬ ការិយាល័យកណ្តាល អគារលេខ២៨៥ មហាវិថី យោធពលខេមរភូមិន្ទ (ផ្លូវ២៧១) សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ឬតាមរយៈ

- E-mail: job@amkcambodia.com
- Telegram: 086 777 130

**ដោយភ្ជាប់ជាមួយ:**

- ថតចម្លងសញ្ញាប័ត្រដែលទទួលបាន ឬលិខិតបញ្ជាក់ពីសាលា / សាកលវិទ្យាល័យ
- ថតចម្លងអត្តសញ្ញាណប័ណ្ណ  សៀវភៅគ្រួសារ ប័ណ្ណប.ស.ស(ប្រសិនបើមាន) និងលិខិតបញ្ជាក់កំណើត
- ថតចំលងតារាងពិន្ទុបញ្ជាក់ការសិក្សាពីសាកលវិទ្យាល័យ (ប្រសិនបើមាន)

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកទូរស័ព្ទលេខ: 086 777 130 ឬគេហទំព័រ  : www.amkcambodia.com

( **អេ អឹម ខេ ផ្តល់ឱកាសស្មើៗគ្នាសម្រាប់បេក្ខជនទាំងអស់! ស្ត្រីនិងជនមានពិការភាពត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យ** )